អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

---

អង្គជំនុំជម្រះតុលាការកំពូល
Supreme Court Chamber
Chambre de la Cour suprême

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ/អ.ជ.ត.ក (១០)

Case File/Dossier N°. 002/19-09-2007-ECCC-TC/SC (10)

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 19-Apr-2012, 10:57
CMS/CFO: Kauv Keoratanak

នៅចំពោះមុខ៖

ចៅក្រម គង់ ស្រ៊ីម ប្រធាន
ចៅក្រម Motoo Noguchi
ចៅក្រម សោម សិរីវុឌ្ឍ
ចៅក្រម Agniezska KLONOWIECKAMILART
ចៅក្រម ម៉ុង មុន្នីចរិយា
ចៅក្រម Chandra Nihal Jayasinghe
ចៅក្រម យ៉ា ណារិន

កាលបរិច្ឆេទឯកសារ៖ ១៩ ខែ មីនា ឆ្នាំ ២០១២
ភាសាដើម៖ ខ្មែរ/អង់គ្លេស
ចំណាត់ថ្នាក់ឯកសារ៖ សាធារណៈ

---

# សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ អៀង សារី ជំទាស់ទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់សហព្រះរាជអាជ្ញាសុំដកលក្ខខណ្ឌតម្រូវ ស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធ ចេញពីនិយមន័យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

---

**សហមេធាវីការពារក្តីជនជាប់ចោទ៖**
អាង ឧត្តម
Michael G. KARNAVAS

**ជនជាប់ចោទ៖**
អៀង សារី

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**
ពេជ អង្គ
Elisabeth SIMONNEAU FORT

**សហព្រះរាជអាជ្ញា៖**

ជា លាង
Andrew CAYLEY

**អង្គជំនុំជម្រះតុលាការកំពូល** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") បានទទួលបណ្តឹងសាទុក្ខភ្លាមៗរបស់ អៀង សារី ("ជនជាប់ចោទ") ជំទាស់ទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលទទួលយកសំណើរបស់សហព្រះរាជអាជ្ញាសុំដកលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធចេញពីនិយមន័យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ("បណ្តឹងសាទុក្ខ")[1]៖

## I. ប្រវត្តិនីតិវិធី

១. នៅថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១ អង្គបុរេជំនុំជម្រះ ("អ.ប.ជ") បានសម្រេចដោយផ្អែកនៅក្នុងសេចក្តីសម្រេចរបស់ខ្លួនលើបណ្តឹងសាទុក្ខប្រឆាំងនឹងដីកាដំណោះស្រាយ[2] ដែលបានសម្រេចថា និយមន័យរបស់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលយកមកអនុវត្តបានក្នុងដែនកំណត់យុត្តាធិការពេលវេលារបស់ អ.វ.ត.ក បានរួមបញ្ចូល"លក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធ (...) ដែលតម្រូវឲ្យមានទំនាក់ទំនងជាមួយឧក្រិដ្ឋកម្មសង្គ្រាម ឬឧក្រិដ្ឋកម្មប្រឆាំងសន្តិភាព មានន័យថា ទំនាក់ទំនងរវាងអំពើជាមូលដ្ឋានដទៃទៀតដែលត្រូវបានចោទប្រកាន់ថា ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងជម្លោះប្រដាប់អាវុធ"[3]។ នៅថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១១ សហព្រះរាជអាជ្ញាបានដាក់សំណើទៅកាន់អង្គជំនុំជម្រះសាលាដំបូង ស្នើសុំកែប្រែដីកាដំណោះស្រាយដែលត្រូវបានកែប្រែនោះ ដើម្បីបញ្ជាក់ថា លក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធ មិនមែនជាធាតុផ្សំនៃ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ("សំណើសុំ")[4] នោះទេ។ នៅថ្ងៃទី ២៦ ខែ តុលា ឆ្នាំ

---

[1] បណ្តឹងសាទុក្ខរបស់លោក អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង លើសំណើរបស់សហព្រះរាជអាជ្ញា សុំដកលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធ ចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ, សំណុំរឿងលេខ. 002/19-09-2007-អ.វ.ត.ក-អ.ជ.ស.ដ/អ.ជ.ត.ក(១០), ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១១, E95/8/1/1។

[2] ដីកាដំណោះស្រាយ, ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០, D427 ("ដីកាដំណោះស្រាយ")។

[3] សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ, អង្គបុរេជំនុំជម្រះ D427/3/15, ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១ ("សាលដីកា អ.ជ.ប"), កថាខណ្ឌ ១៤៤។

[4] សំណើរបស់សហព្រះរាជអាជ្ញា សុំឲ្យអង្គជំនុំជម្រះសាលាដំបូង ដកលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនង នៃជម្លោះប្រដាប់អាវុធចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ, E95, ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១១។

២០១១ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចតាមសំណើសុំនេះ (“សេចក្តីសម្រេចដែលរងការការជំទាស់”)[5]។

២. នៅថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១១ សហមេធាវីការពារក្តីរបស់ អៀង សារី (មេធាវីការពារក្តី) បានដាក់បណ្តឹងសាទុក្ខ។ នៅថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១១ សហព្រះរាជអាជ្ញាបានដាក់សារណាតប[6] ហើយនៅថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១១ មេធាវីការពារក្តីបានដាក់ការឆ្លើយតប[7]។

## II. សារណា

### ក. **<u>ភាពអាចទទួលយកបាន</u>**

៣. មេធាវីការពារក្តីលើកឡើងថា បណ្តឹងសាទុក្ខអាចទទួលយកបាន អនុលោមតាមវិធាន ១០៤ (៤) (ក)នៃវិធានផ្ទៃក្នុង ដោយវិធាននេះផ្តល់សិទ្ធិឲ្យដាក់បណ្តឹងសាទុក្ខភ្លាមៗជំទាស់នឹងសេចក្តីសម្រេចដែល“មានអនុភាពបញ្ចប់កិច្ចដំណើរការនីតិវិធី”។ មេធាវីការពារក្តីសង្កេតឃើញថា នៅក្នុងដីកាសម្រេចរបស់ខ្លួននៅថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានបំបែកសវនាការនៅក្នុងសំណុំរឿង ០០២ ឲ្យទៅជា “សំណុំរឿង” ដោយឡែកផ្សេងៗគ្នា (“ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី”)[8]។ លើសពីនេះទៀត មេធាវីការពារក្តីសង្កេតឃើញថា សវនាការលើកដំបូងដែលចេញពីដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីនេះ ត្រូវបានកម្រិតត្រឹមឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលកើតមាននៅក្នុងការជម្លៀសប្រជាជនពីដំណាក់កាលទី ១ និងដំណាក់

---

5 សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា សុំដកលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធ ចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ, ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០១១, E95/8។

6 ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលដកលក្ខខណ្ឌតម្រូវឲ្យមានទំនាក់ទំនងជាមួយជម្លោះប្រដាប់អាវុធចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ, ថ្ងៃទី០២ ខែ ធ្នូ ឆ្នាំ ២០១១, E95/8/1/2។

7 សំណើរបស់ អៀង សារី សុំអនុញ្ញាតដាក់ការឆ្លើយតប និងការឆ្លើយតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលដកលក្ខខណ្ឌតម្រូវឲ្យមានទំនាក់ទំនងជាមួយប្រដាប់អាវុធ ចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ, ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១១, E95/8/1/3។

8 ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩ *ស្ទួនពីរ* នៃវិធានផ្ទៃក្នុង, ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១, E124។

កាលទី ២[9]។ ដោយសារសវនាការលើកដំបូងនេះ មិនពិចារណាទៅលើភស្តុតាងណាមួយពាក់ព័ន្ធទៅនឹងលក្ខខណ្ឌនៃទំនាក់ទំនងរវាងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ និងជម្លោះប្រដាប់អាវុធនោះ មេធាវីការពារក្តីអះអាងថា កិច្ចដំណើរការនីតិវិធីនឹងត្រូវបញ្ចប់ "ដោយស្វ័យប្រវត្តិ" ដោយសារតែខ្វះភស្តុតាង ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងបដិសេធទៅលើសំណើរបស់សហព្រះរាជអាជ្ញា ហើយសម្រេចថា លក្ខខណ្ឌទំនាក់ទំនងនោះ គឺជាធាតុផ្សំមួយនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[10]។ លើសពីនេះទៀត មេធាវីការពារក្តីអះអាងថា អង្គជំនុំជម្រះសាលាដំបូងមិនអាចទទួលយកភស្តុតាងថ្មី "នៅក្នុងដំណាក់កាលក្រោយនេះ" ដោយគ្មានប៉ះពាល់ដល់សិទ្ធិរបស់ជនត្រូវចោទក្នុងការទទួលបានការកាត់សេចក្តីដោយយុត្តិធម៌នោះទេ[11]។ ចុងបញ្ចប់ មេធាវីការពារក្តីអះអាងថា ប្រសិនបើអង្គជំនុំជម្រះនេះខកខានមិនបានសម្រេចឲ្យបានជាក់លាក់ពីនិយមន័យរបស់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឲ្យបានមុនពេលសវនាការទេនោះ នោះការខកខាននេះនឹងធ្វើឲ្យប៉ះពាល់ដល់សិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជូនដំណឹងអំពីរឿងក្តីប្រឆាំងនឹងខ្លួន[12]។ មេធាវីការពារក្តីស្នើសុំឲ្យមានសវនាការផ្ទាល់មាត់ជាសាធារណៈមួយ[13]។

៤. សហព្រះរាជអាជ្ញាឆ្លើយតបថា អត្ថន័យយ៉ាងសាមញ្ញរបស់វិធាន ១០៤(៤)(ក) នៃវិធានផ្ទៃក្នុងពិចារណាតែទៅលើបណ្តឹងសាទុក្ខជំទាស់នឹងសេចក្តីសម្រេច ដែលបញ្ចប់កិច្ចដំណើរការនីតិវិធីប៉ុណ្ណោះ។ ដោយសារ សេចក្តីសម្រេចដែលត្រូវបានជំទាស់ មិនបញ្ចប់កិច្ចដំណើរការនីតិវិធីទេនោះ សហព្រះរាជអាជ្ញាអះអាងថា បណ្តឹងសាទុក្ខនេះមិនអាចទទួលយកបាន អនុលោមតាមវិធាន ១០៤(៤)(ក) នៃវិធានផ្ទៃក្នុងទេ[14]។

---

9 ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី កថាខណ្ឌ ៥។ *សូមមើល* ដីកាដំណោះស្រាយ កថាខណ្ឌ ២២១-២៨២ (កំណត់យកការជម្លៀសប្រជាជនដំណាក់កាលទី១ កើតមាននៅក្នុងឆ្នាំ ១៩៧៥ នាទីក្រុងភ្នំពេញ និងការជម្លៀសប្រជាជនដំណាក់កាលទី២ កើតមាននៅភូមិភាគមជ្ឈិម ភូមិភាគនិរតី និងភូមិភាគបស្ចិម ក្នុងចន្លោះពីឆ្នាំ ១៩៧៥ និងឆ្នាំ១៩៧៧)។

10 បណ្តឹងសាទុក្ខ, កថាខណ្ឌ ១០-១២។

11 បណ្តឹងសាទុក្ខ, កថាខណ្ឌ ១២។

12 បណ្តឹងសាទុក្ខ, កថាខណ្ឌ ១៣-១៥។

13 បណ្តឹងសាទុក្ខ, កថាខណ្ឌ ១៩។

14 សារណាតប, កថាខណ្ឌ ៤។

៥. នៅក្នុងចម្លើយតបរបស់ខ្លួនវិញ មេធាវីការពារក្តីអះអាងថា ដើម្បីការពារសមភាពនៃមធ្យោបាយក្នុងការតទល់ក្តី ព្រមទាំងរក្សាតុល្យភាពរវាងសិទ្ធិរបស់សហព្រះរាជអាជ្ញា និងមេធាវីការពារក្តីក្នុងការដាក់បណ្តឹងឧទ្ធរណ៍ វិធាន ១០៤(៤)(ក)នៃវិធានផ្ទៃក្នុង ចាំបាច់ត្រូវតែបកស្រាយ ដើម្បីរួមបញ្ចូលសេចក្តី សម្រេចទាំងនោះដែលអាចនឹងបញ្ចប់កិច្ចដំណើរការនីតិវិធី ប្រសិនបើលទ្ធផលចេញមកខុសគ្នានោះ[15]។

## ខ. អង្គសេចក្តី

៦. មេធាវីការពារក្តីអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសនៅក្នុងការបកស្រាយ ស្តីពីប្រភពពាក់ព័ន្ធនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ[16] និងមិនបានពិចារណា ថាតើនៅអំឡុងពេលនោះជនជាប់ចោទដឹងថា មានច្បាប់ចែង និងដឹងថាជាអំពើឧក្រិដ្ឋ ដែរ ឬយ៉ាងណា[17] ទោះបីជាច្បាប់ទំនៀមទម្លាប់ មិនតម្រូវឲ្យមានលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងជាមួយជម្លោះប្រដាប់អាវុធក្នុងអំឡុងពីឆ្នាំ ១៩៧៥ និងឆ្នាំ ១៩៧៩ ក៏ដោយ។ សហព្រះរាជអាជ្ញាមិនបានឆ្លើយតបទៅនឹងទឡ្ហីករណ៍របស់មេធាវីការពារក្តីស្តីអំពីអង្គសេចក្តីរបស់បណ្តឹងសាទុក្ខ ឡើយ។

## III. ការពិចារណា

៧. អនុលោមតាមវិធាន ១០៩(១) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះតុលាការកំពូល យល់ឃើញថាសារណាជាលាយលក្ខណ៍អក្សរ មានលក្ខណៈគ្រប់គ្រាន់នៅក្នុងករណីនេះ ហើយពុំចាំបាច់មានសវនាការជាសាធារណៈនោះទេ។

## ក. ភាពអាចទទួលយកបាន

៨. អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា បណ្តឹងសាទុក្ខនេះមិនស្ថិតក្នុងវិសាលភាពនៃវិធាន ១០៤(៤)(ក) នៃវិធានផ្ទៃក្នុងនោះទេ ដែលវិធាននេះកម្រិតត្រឹមតែបណ្តឹងសាទុក្ខចំពោះសេចក្តីសម្រេចដែល"មានអានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធី"[18]។ សេចក្តីសម្រេចរងការជំទាស់នេះ

---

[15] សារណាតប។

[16] បណ្តឹងសាទុក្ខ, កថាខណ្ឌ ២៧-៥៦។

[17] បណ្តឹងសាទុក្ខ, កថាខណ្ឌ ៥៧-៦១។

[18] សារណាតរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ៤។

មិនមានអានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធីនោះទេ។ ការលើកឡើងរបស់មេធាវីការពារក្តីដែលថា បណ្តឹងសាទុក្ខនេះអាចទទួលយកបាន ដោយហេតុថា សេចក្តីសម្រេចដែលរងការជំទាស់នេះ នឹងអាចបញ្ចប់កិច្ចដំណើរការនីតិវិធីនៅដំណាក់កាលដំបូងនៃការជំនុំជម្រះក្នុងសំណុំរឿង ០០២ ដោយសារតែអង្គជំនុំជម្រះសាលាដំបូងមានកំហុសនោះ មិនមានមូលដ្ឋាននៅក្នុងអត្ថន័យនៃវិធាន ១០៤(៤)(ក) នៃវិធានផ្ទៃក្នុងឡើយ។

៩. គោលការណ៍តុល្យភាពនៃកំលាំងក្នុងការតទល់ក្តី មិនត្រូវបានរំលោភបំពានដោយវិធាន ១០៤(៤)(ក) នោះទេដោយវិធាននេះ មាលក្ខណៈអព្យាក្រឹត្យ និងបានផ្តល់សិទ្ធិដល់ធ្វើបណ្តឹងសាទុក្ខដល់ភាគីណាមួយ ដែលមានផលប្រយោជន៍ផ្លូវច្បាប់ ក្នុងការធ្វើប្តឹងសាទុក្ខលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានអានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធី[19]។ លើសពីនេះទៀត តុល្យភាពនៃកំលាំងក្នុងការតទល់ក្តី មិនបានកំណត់ថា សិទ្ធិនៅក្នុងដំណើរការនីតិវិធីក្នុងការចោទប្រកាន់ និងការការពារក្តី ត្រូវតែដូចគ្នាបេះបិទគ្រប់ពេលនោះទេ[20]។ សិទ្ធិធ្វើបណ្តឹងសាទុក្ខ ដែលមានចែងក្នុងវិធាន ១០៤(៤)(ក) នៃវិធានផ្ទៃក្នុង ធានាថា បណ្តឹងសាទុក្ខមួយអាចកើតមាន នៅពេលដែលកិច្ចដំណើរការនីតិវិធីត្រូវបានបញ្ចប់ ដោយពុំបានចេញសាលក្រម និងដោយពុំមានឱកាសធ្វើ ណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមនេះ។ ផ្ទុយទៅវិញ នៅពេលដែលអង្គជំនុំជម្រះសាលាដំបូង បដិសេធសំណើសុំបញ្ចប់កិច្ចដំណើរការនីតិវិធី ភាគីពាក់ព័ន្ធ អាចជំទាស់សេចក្តីសម្រេចនេះបាន ដែលជាផ្នែកមួយនៃសាលក្រម[21]។ លើសពីនេះទៀត មាត្រា ១៤ (៥) នៃកតិកា

---

[19] ឧទាហរណ៍មេធាវីការពារក្តីអាចធ្វើបណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលផ្អាក់កិច្ចដំណើរការនីតិវិធី ហើយអាចស្នើសុំឱ្យធ្វើការលើកលែងបទចោទជំនួសវិញ។ *សូមមើល* សេចក្តីសម្រេចស្តីពីបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងដីកាបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូងឱ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ ឯកសារលេខ E138/1/7 កថាខណ្ឌ ១៥ (វិធាន ១០៤(៤)(ក) នៃវិធានផ្ទៃក្នុង អនុញ្ញាតបណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលផ្អាក់កិច្ចដំណើរការនីតិវិធី នៅពេលដែលពុំអាចនឹងបន្តកិច្ចដំណើរការនេះទៀតបាន)។

[20] *សូមមើលរឿងក្តីរដ្ឋអាជ្ញា ទល់នឹង kordic Cerkez,* សំណុំរឿងលេខ IT-95-14/2-A "សេចក្តីសម្រេចលើសំណើរបស់ Mario Cerkez សុំពន្យារពេលដាក់សារណាតបរបស់ខ្លួន", អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០១១ កថាខណ្ឌ ៦ ដល់៩ (សេចក្តីសម្រេចអនុញ្ញាតអយ្យការ ប៉ុន្តែមិនអនុញ្ញាតផ្តល់ពេលវេលាបន្ថែមដល់ជនជាប់ចោទ ដាក់សារណាតប សេចក្តីសម្រេចនេះ មិនបានរំលោភលើគោលការតុល្យភាពនៃកំលាំងតទល់ក្តី ពីព្រោះអយ្យការ បង្ហាញ "ហេតុផលល្អ"។ គោលការណ៍តុល្យភាពកំលាំងតទល់ក្តីតម្រូវឱ្យមាន"តុល្យភាពត្រឹមត្រូវ"រវាងសិទ្ធិរបស់ភាគីទាំងឡាយ)។

[21] វិធាន ១០៤(១) នៃវិធានផ្ទៃក្នុង។

សញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋនិងនយោបាយ ចែងថា ជនណាដែលជាប់ពិរុទ្ធពីបទព្រហ្មទណ្ឌណាមួយនោះ ត្រូវមានសិទ្ធិប្តឹងទៅតុលាការជាន់ខ្ពស់ឱ្យពិនិត្យឡើងវិញពីពិរុទ្ធភាព និងការផ្តន្ទាទោសរបស់ខ្លួន ដោយអនុលោមទៅតាមច្បាប់ មាត្រានេះមានការជាប់ពាក់ព័ន្ធទៅនឹងសិទ្ធិធ្វើបណ្តឹងសាទុក្ខប្រឆាំងនឹងពិរុទ្ធភាព និងការផ្តន្ទាទោស ប៉ុន្តែមិនពាក់ព័ន្ធទៅនឹងសេចក្តីសម្រេចបន្ទាន់បន្ទំឡើយ[22]។ អំណះអំណាងរបស់មេធាវីការពារក្តី គ្មានសំអាងផ្លូវច្បាប់គ្រប់គ្រាន់ឡើយ។

១០. លើសពីនេះទៀត មេធាវីការពារក្តីមិនបានបង្ហាញថា ប្រសិនបើអង្គជំនុំជម្រះតុលាការកំពូលមិនដោះស្រាយទៅលើបញ្ហាអង្គសេចក្តីរបស់បណ្តឹងសាទុក្ខនាពេលបច្ចុប្បន្ននេះ ជនជាប់ចោទនឹងត្រូវបាត់បង់សិទ្ធិក្នុងការយល់ដឹងអំពីរឿងក្តីប្រឆាំងនឹងខ្លួន។ ចំពោះការជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌ មិនមានអ្វីខុសប្លែកពីនោះទេ ក្នុងការដែលមានការជាប់ពាក់ព័ន្ធទៅនឹងការជំទាស់តវ៉ាលើបញ្ហាច្បាប់ប្រើប្រាស់យុត្តិសាស្ត្រខុសៗគ្នា។ ដោយហេតុថា គ្រប់ករណីទាំងអស់ អង្គជំនុំជម្រះសាលាដំបូងមិនត្រូវបាន ចងកាតព្វកិច្ចដោយការកំណត់បទចោទដែលបានធ្វើឡើយដោយអង្គបុរេជំនុំជម្រះ[23] កម្រិតនៃភាពមិនច្បាស់លាស់នៅក្នុងរឿងក្តីប្រឆាំងនឹងជនជាប់ចោទ មិនមានអ្វីខុសប្លែកពីធម្មតានោះទេ។

**យោងសំអាងហេតុនានាខាងលើ** អង្គជំនុំជម្រះតុលាការកំពូល៖

**បដិសេធ** សំណើសុំឱ្យមានសវនាការផ្ទាល់មាត់ និង

**សម្រេច** បដិសេធបណ្តឹងសាទុក្ខនេះ។

---

22 *សូមមើល រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Norman*, សំណុំរឿងលេខ SCSL-2003-08-PT, “សេចក្តីសម្រេចស្តីពីសំណើសុំផ្អាកកិច្ចដំណើរការនីតិវិធី និងការបដិសេធសិទ្ធិធ្វើបណ្តឹងសាទុក្ខ”, អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០០៣ កថាខណ្ឌ ១៨ ដល់ ២៥។

23 វិធាន ៩៨(២)នៃវិធានផ្ទៃក្នុង។

ភ្នំពេញ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១២

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

**គង់ ស្រ៊ីម**